**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ១០៥ **ក.ប**/ស.ជ.ណ.ខ.ល

# សេចក្តីជូនដំណឹង

យោងលិខិតលេខ ៥៨១ គ.ជ.ប ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស និងរោងចក្រធំៗនៅតាមបណ្តាខេត្តនានា ឱ្យបានជ្រាបថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានសហការជាមួយអង្គការ JICA នឹងចុះធ្វើសកម្មភាពផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ ខាងមុខនេះ។ ដើម្បីឱ្យការផ្សព្វផ្សាយអប់រំនេះបានទូលំទូលាយ សូមម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស និងរោងចក្រធំៗនៅតាមបណ្តាខេត្តនានា មេត្តាសហការជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជាធរមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានក្នុងតំបន់សេដ្ឋកិច្ចពិសេស ក៏ដូចជាបណ្តារោងចក្រធំៗនៅតាមខេត្តទាំងអស់អនុវត្តតាមខ្លឹមសារសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

ចម្លងជូនៈ
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩